# ទស្សនទានរបស់សេដ្ឋវិទូសំខាន់ៗ

*ដោយលោក ប៉ាន់ វុត្ថា*
*(បណ្ឌិតផ្នែកទស្សនវិជ្ជា)*
*មន្ត្រីស្រាវជ្រាវផ្នែកទស្សនវិជ្ជានិងសង្គមវិទ្យា*
*វិទ្យាស្ថានមនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម*

*តើត្រូវធ្វើដូចម្តេចដើម្បីឱ្យសេដ្ឋកិច្ចដំណើរការល្អ និង មានការរីកចម្រើន ?*
*ដើម្បីឱ្យសេដ្ឋកិច្ចដំណើរការល្អ និង មានការរីកចម្រើនៈ*

*១-តាម* ***ប្លាតុង*** *តម្រូវឱ្យមនុស្សម្នាក់ៗបំពេញមុខងារទៅតាមឯកទេសកម្ម ហើយទទួលបន្ទុកការងារតែមួយមុខៗ មនុស្សខុសៗគ្នា មានសមត្ថភាពខុសៗគ្នា ត្រូវដាក់ឱ្យបំពេញមុខងារខុសៗគ្នានៅក្នុងសង្គម តែពួកគេបំពេញឱ្យគ្នាពីមួយទៅមួយដើម្បីឱ្យគ្រប់ៗគ្នា ចូលរួមនៅក្នុងការផ្គត់ផ្គង់នូវតម្រូវការធម្មជាតិនានារបស់មនុស្សទៅវិញទៅមក។*

*២-តាម* ***ចន លក*** (John Locke, *១៦៣២-១៧០៤*) *ជាជនជាតិអង់គ្លេសថា រដ្ឋត្រូវបង្កើតច្បាប់កម្មសិទ្ធិឯកជន ដើម្បីការពារកម្មសិទ្ធិឯកជន ទើបមនុស្សខិតខំធ្វើការ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន។*

*៣-តាម* ***ចច វីល្ហិម ហ្វ្រីដ្រិច ហេហ្គែល*** (George Wilhelm Friedrich Hegel, *១៧៧០-១៨៣១*) *ជាជនជាតិអាល្លឺម៉ង់ថា មនុស្សអភិវឌ្ឍធម្មជាតិ ហើយធម្មជាតិ អភិវឌ្ឍមនុស្សទៅវិញទៅមកក្នុងលក្ខណៈជារង្វង់វិលវៀន។ ការអភិវឌ្ឍ គឺដោយសារម្ចាស់កម្លាំងផលិតកម្មជាអ្នករៀបចំគម្រោងផ្តល់គំនិតដឹកនាំ*

និងគ្រប់គ្រងផលិតកម្ម មានន័យថា សេដ្ឋកិច្ចដើរដោយក្បាលម្ចាស់កម្លាំងផលិតកម្ម។

៨-តាម **កាល ម៉ាក្ស** (Karl Marx, ១៨១៨-១៨៨៣) ជាជនជាតិអាល្លឺម៉ង់ថា សេដ្ឋកិច្ចដើរ លុះត្រាតែមនុស្សមានការងារធ្វើ ទើបមានលុយចាយ ទើបមានតម្រូវការ ទើបមានផលិតកម្ម។ សេដ្ឋកិច្ចដើរដោយដៃជើងរបស់កម្មករ។

៩-តាម **អាដាម ស្មីត** (Adam Smith, ១៧២៣-១៧៩០) ជាជនជាតិស្កុតថាៈ

- មនុស្សត្រូវប្រែក្លាយ មាស ប្រាក់ លុយ ទៅជាមុខរបរមានចំណូលចំណេញ។
- រដ្ឋ និង ភ្នាក់ងារសេដ្ឋកិច្ចម្នាក់ៗ មានទំនាក់ទំនងតាមរយៈបាតដៃអរូបី។
- រដ្ឋ ត្រូវបង្កើតបរិយាកាសប្រកួតប្រជែងដោយតម្លាភាព សេរី សុក្រិត្យ និង យុត្តិធម៌ ដើម្បីឱ្យភ្នាក់ងារសេដ្ឋកិច្ចម្នាក់ៗក្នុងគ្រប់វណ្ណៈទាំងអស់ទទួលបានអត្ថប្រយោជន៍ផ្ទាល់ខ្លួនជាអតិបរមា ទៅតាមការខិតខំប្រឹងប្រែងផ្ទាល់ខ្លួន។ ការប្រកួតប្រជែង នាំឱ្យបង្កើតបានជាផលិតករល្អៗ មានសមត្ថភាពបំពេញនូវសេចក្តី ត្រូវការរបស់អ្នកប្រើប្រាស់បានតាមសំណូមពរ។
- ភាពសម្បូរ ឬ ភាពក្រខ្សត់ គឺអាស្រ័យដោយចាំបាច់ទៅលើ ចំនួនពលករធ្វើការមានប្រយោជន៍ និង ការងារមានប្រយោជន៍ ហើយបានផលគ្រប់កន្លែង។
- អំណាចនៃសេដ្ឋកិច្ចមួយ វាអាស្រ័យលើចំនួនមនុស្សធ្វើការ ពោលគឺប្រជាពលរដ្ឋសកម្មដែលមានការងារធ្វើ។

- នវានុវត្តន៍ ការកែច្នៃរបៀបធ្វើការងារ ការបែងចែកកម្លាំងពលកម្ម ធ្វើកិច្ចការមួយជាផ្នែកតូចៗ ធ្វើឱ្យកម្មករទទួលបានផលិតភាពខ្ពស់ និងជាគ្រឹះនៃដើមកំណើតតម្លៃផ្សេងៗផងដែរ។

- ភ្នាក់ងារសេដ្ឋកិច្ចម្នាក់ៗត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ខ្ជាប់ខ្ជួន។

៦-តាម **ថូម៉ាស រ៉ូប៊ើត ម៉ាលទុស** (Thomas Robert Malthus, ១៧៦៦-១៨៣៤) ជាជនជាតិអង់គ្លេសថា គេត្រូវបន្ថយអត្រាកំណើនប្រជាជន ហើយបង្កើនអត្រាកំណើនសេដ្ឋកិច្ច ទើបគេអាចយកផលិតកម្មលើស ទៅប្រើប្រាស់ធ្វើទុនវិនិយោគទៀតបាន។

៧-តាម **ដាវីដ រីកាដូ** (David Ricardo, ១៧៧២-១៨២៣) ជាជនជាតិអង់គ្លេសថា មេគ្រួសារ មិនដែលមានបំណងផលិតនៅក្នុងផ្ទះនូវទំនិញដែលអស់ថ្លៃដើមច្រើនជាងទិញពីខាងក្រៅទេ។ ភ្នាក់ងារសេដ្ឋកិច្ចម្នាក់ៗត្រូវចាប់យកឧត្តមភាពក្នុងផលិតកម្មរបស់ខ្លួន ហើយធ្វើការដោះដូរពាណិជ្ជកម្មជាមួយគ្នា ទើបអាចទទួលបានកំណើនសេដ្ឋកិច្ច។

៨-តាម **ចន ម៉ៃណាត កេនស៍** (John Maynard Keynes, ១៨៨៣-១៩៤៦) ជាជនជាតិអង់គ្លេស អះអាងថា មូលហេតុចម្បងនៃដំណើរប្រែប្រួលសេដ្ឋកិច្ច គឺ កើតចេញពីការសន្សំ និង ការវិនិយោគ។

សន្សំ > វិនិយោគ → ខ្វះទំនិញ → មានវិបត្តិសេដ្ឋកិច្ច → អតិផរណា។

សន្សំ < វិនិយោគ → លើសទំនិញ → មានវិបត្តិសេដ្ឋកិច្ច។

**កេនស៍** បានអះអាងថា ដើម្បីរក្សាអថេរទាំងពីរនេះឱ្យស្មើគ្នានៅក្នុងកម្រិតណាមួយនោះ ធនាគារកណ្តាលត្រូវទទួលខុសត្រូវ៖ ប្រសិនបើ ការសន្សំលើសការវិនិយោគនោះ ធនាគារកណ្តាលត្រូវបញ្ចុះអត្រាការប្រាក់ ដើម្បីកាត់បន្ថយសន្សំ និង ជំរុញកម្ចី។ ម្យ៉ាងទៀត ប្រសិនបើការសន្សំទាបជាង ការវិនិយោគ

នោះ ធនាគារកណ្តាលត្រូវបង្កើនអត្រាការប្រាក់ដើម្បីជំរុញការសន្សំ និងកាត់បន្ថយកម្ចី សម្រាប់គោលដៅវិនិយោគ។ អន្តរាគមន៍របស់រដ្ឋាភិបាលដើម្បីធ្វើឱ្យមានស្ថិរភាពនៃការវិនិយោគ គឺ៖ នៅពេលដែលការវិនិយោគឯកជនមានកម្រិតទាប រដ្ឋគួរខ្ចីប្រាក់ និងចូលរួមនៅក្នុងកិច្ចការវិនិយោគសាធារណៈ ដូចជា ការកសាងស្ពាន ផ្លូវ សាលារៀន មន្ទីរពេទ្យ និង បង្កើនចំណាយទៅលើការអប់រំ និងសេវាសាធារណៈ។ ទង្វើបែបនេះ នឹងពង្រីកសេដ្ឋកិច្ច និង ធ្វើឱ្យប្រសើរឡើងនូវការរំពឹងទុកចំពោះអនាគត។ ផ្ទុយទៅវិញ នៅពេលដែលការវិនិយោគរបស់សហគ្រាសមានកម្រិតខ្ពស់ ដោយសារសុទិដ្ឋិនិយមដ៏ខ្លាំងក្លា រដ្ឋគួរបញ្ឈប់កម្ចី និង កាត់បន្ថយការវិនិយោគសាធារណៈ។ **កេនស៍** តម្រូវឱ្យរក្សាអត្រាប្តូរប្រាក់ថេរ ព្រោះ វាជាប្រភពនៃលំនឹង និង ភាពជាក់ច្បាស់សេដ្ឋកិច្ច។

៩-តាម **ស៊ីម៉ុន គូសញៀត** (Simon KUZNETS, ១៩០១-១៩៨៥) បានគូសបញ្ជាក់ពីកំណើន និង ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងខួប២០ឆ្នាំថា៖ ការកើនឡើងចំនួនប្រជាជន អាចបណ្តាលមកពីអន្តោប្រវេសន៍ ឬ អត្រាកំណើត ដោយសារកាលៈទេសៈអនុគ្រោះខាងសេដ្ឋកិច្ច។ កំណើនប្រជាជននឹងនាំឱ្យមានតម្រូវការកើនឡើងចំពោះទំនិញប្រើប្រាស់ ជាពិសេស ការសាងសង់លំនៅដ្ឋាន របស់ប្រើប្រាស់ គ្រឿងកំសាន្ត អាហារ។ល។ តម្រូវការបន្ថែមនឹងនាំឱ្យមានការវិនិយោគបន្ថែម។ មូលហេតុនេះ រួមផ្សំជាមួយនឹងសមត្ថភាព ដើម្បីទទួលបាននូវគុណសម្បត្តិនៃវិមាត្រសេដ្ឋកិច្ច នឹងជំរុញឱ្យមានកំណើនផលិតភាពឆាប់រហ័ស។ ហើយកម្រិតជីវភាពក៏កើនឡើងទន្ទឹមនឹងចំនួនប្រជាជនកើនឡើង ក្នុងអំឡុងពេលពីឆ្នាំទី១ទៅឆ្នាំទី១៥-១៦ដែរ។ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ ចំនួនប្រជាជនដែលកើនឡើងថ្មី នឹងធ្វើឱ្យកម្លាំងពលកម្មកាន់តែរីកធំផងដែរ ប្រការនេះនឹងក្លាយជាសម្ពាធនាំឱ្យថ្លៃឈ្នួលពលកម្មមានទំនោរធ្លាក់ចុះ។ ដោយសារការ

ធ្លាក់ចុះថ្លៃឈ្នួលកម្លាំងពលកម្ម ចំណាយ និង ការវិនិយោគក៏ធ្លាក់ចុះ ដែលនោះជានិន្នាការបញ្ចប់ខួបសេដ្ឋកិច្ចៗ ដូច្នេះ គេត្រូវបង្កើតខួបសេដ្ឋកិច្ចថ្មីទៀត។

១០-តាម **ហ្សូហ្សេហ្វ ស្ស៊ូមពីទ័រ** (Joseph SCHUMPETER, ១៨៨៣-១៩៥០, ម៉ូរ៉ាវៀ-ឆែក) បានអះអាងថា៖

- តក្កកម្ម ឬ ប្រឌិតញាណ (Invention) នវានុវត្តន៍ ដែលបង្កើតឡើងដោយសហគ្រិន និង មានការគាំទ្រដោយឥណទានធនាគារ ជាកម្លាំងជំរុញកំណើនសេដ្ឋកិច្ច។
- ការបំផ្លាញក្នុងលក្ខណៈមាបនកម្ម ជាមូលហេតុដំចម្បងមួយសម្រាប់ជោគជ័យសេដ្ឋកិច្ច។

១១-តាម **មីលតុន ហ្វ្រីដមែន** (Milton Friedman, ១៩១២-...) ជាជនជាតិជ្វីសយល់ថា៖ សេដ្ឋកិច្ចមានដំណើរការកាន់តែប្រសើរឡើង តាមរយៈលុយចរាចរណ៍មានល្បឿនលឿន និង ច្រើនដុំៗ **ហ្វ្រីដមែន** បានលើកទឡ្ហីករណ៍ថា អត្រាប្តូរប្រាក់ប្រែប្រួល ត្រូវបានគេពេញនិយមជាងអត្រាប្តូរប្រាក់ថេរ ព្រោះ៖

ទី១-ជាមួយនឹងអត្រាប្តូរប្រាក់ថេរ ប្រទេសនានាអាចប្រើប្រាស់គោលនយោបាយរូបិយវត្ថុ ដើម្បីរក្សារូបិយប័ណ្ណជាតិឱ្យស្ថិតនៅក្នុងអត្រាថេរ។ ធនាគារកណ្តាល ត្រូវបានគេបង្ខំឱ្យបង្កើតសាច់ប្រាក់ច្រើនសន្ធឹកសន្ធាប់ពេកក្នុងគោលបំណងទិញរូបិយប័ណ្ណបរទេសនានា និង រក្សាឱ្យមានអត្រាប្តូរប្រាក់ថេរ។ អត្រាប្តូរប្រាក់ដែលចេះតែប៉ោងឡើង ធ្វើឱ្យអជ្ញាធររូបិយវត្ថុ យកចិត្តទុកដាក់ទៅលើគោលនយោបាយរូបិយវត្ថុ ដោយគ្មានការបារម្ភអំពីតម្លៃរូបិយប័ណ្ណជាតិ។ ផ្ទុយទៅវិញ ជាមួយ អត្រាប្តូរប្រាក់ប្រែប្រួល អាចជៀសវាងបញ្ហានេះបាន។

ទី៦- **ហ្វ្រីដមែន** បាន លើកឡើងថា អត្រាប្តូរប្រាក់ប្រែប្រួលបានជួយជំរុញការធ្វើពាណិជ្ជកម្ម អាចកែតម្រូវដោយស្វ័យប្រវត្តិ ឆ្លើយតបទៅនឹងឱនភាពពាណិជ្ជកម្មក្នុងប្រទេសនានា។ អត្រាប្តូរប្រាក់ប្រែប្រួលបានរក្សាអតិផរណាមិនឱ្យគេនាំចេញពីប្រទេសមួយ ទៅប្រទេសមួយទៀត។ ផ្ទុយទៅវិញ ក្រោមប្រព័ន្ធអត្រាប្តូរប្រាក់ថេរ ប្រទេសនានាដែលកំពុងជួបប្រទះនឹងអតិផរណា នឹងទិញទំនិញដែលផលិតដោយបរទេសកាន់តែច្រើនឡើង ពីព្រោះវាមានតម្លៃថោកជាង។ ប្រការនេះ ធ្វើឱ្យកើនឡើងនូវចំណាយសម្រាប់ទំនិញក្នុងប្រទេសផ្សេងៗទៀត ហើយបណ្តាលឱ្យមានអតិផរណាកាន់តែខ្លាំងឡើងក្នុងប្រទេស។

១២-តាម **រ៉ៃ ម៉ុន អារ៉ុន** (Ray mond Aron) ដើម្បីធ្វើឱ្យសេដ្ឋកិច្ចដំណើរការល្អ និងមានកំណើន ត្រូវបញ្ចូលពលកម្មឱ្យបានច្រើនទៅក្នុងសង្វាក់ផលិតកម្ម។ ផលិតផលកើតចេញពីពលកម្ម។ ទ្រព្យសម្បត្តិរបស់ប្រទេសមួយ មិនមែនស្ថិតនៅត្រង់មានទឹកដីមានដីជាតិ ឬ មានធនធានធម្មជាតិទេ ប៉ុន្តែស្ថិតនៅលើពលកម្មផលិតកម្ម។ ពលកម្មផលិតកម្មគឺជាមាស ជាប្រាក់ ជាលុយ ជាកំណប់។ គ្រាប់ពូជបាចចោលលើដីមានដីជាតិមួយកន្លែង ប៉ុន្តែគ្មានការថែទាំសោះ ពូជដើមនឹងត្រូវបាត់ស្ទើរគ្មានសល់។ បើគេបន្ថែមពលកម្មថែទាំទៀត នោះគេនឹងបានទិន្នផលខ្ពស់ជាង។ បន្ថែមពលកម្ម២ ឬ ៣ដងថែមទៀត នោះទិន្នផលមិនត្រឹមតែមានកំណើនទ្វេគុណ-ត្រីគុណទេ តែគុណនឹង៤ គុណនឹង៥ ដូច្នេះពូជដើមវាកើនតាមស្វីតធរណីមាត្រ។ បើគេបង្កើនទាំងពូជ ទាំងផ្ទៃដីបង្កបង្កើនផល ទាំងពលកម្ម នោះកំណើនផលិតភាពនឹងកើនខ្ពស់ឡើងៗ។

១៣- តាម **រ៉ូស្តូវ** (W.W Rostow ជនជាតិរូស្ស៊ី) បានរកឃើញថា ដើម្បីធ្វើឱ្យសេដ្ឋកិច្ចដំណើរការល្អ និង មានកំណើន វាត្រូវឆ្លងកាត់៥តំណាក់កាលៈ

- តំណាក់កាលទី១៖ ការស្រាវជ្រាវរកប្រឌិតញាណថ្មីៗ គំនិតកាលានុវត្តភាព និង គំនិតនវានុវត្តន៍។

- តំណាក់កាលទី២៖ ផ្សព្វផ្សាយអប់រំ បញ្ជ្រាបគំនិតអភិវឌ្ឍន៍ បង្រៀនបច្ចេកទេសធ្វើការងារ បណ្ដុះធន្ធៈក្លាហាន មនសិការការងារ និង សីលធម៌វិជ្ជាជីវៈទៅដល់មនុស្សគ្រប់ស្រទាប់វណ្ណៈ។

-តំណាក់កាលទី៣៖ ការត្រៀមលក្ខខណ្ឌសំខាន់ៗសម្រាប់ពេលចេញដំណើរ ដូចជា រៀបចំក្បាលម៉ាស៊ីនដឹកនាំ រចនាសម្ព័ន្ធមនុស្សធ្វើការងារ ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន ប្រព័ន្ធធារាសាស្ត្រ ទឹក ភ្លើង គ្រឿងចក្រ ។ល។

- តំណាក់កាលទី៤៖ ផលិតកម្ម។ ភ្នាក់ងារផលិតកម្មទាំងអស់ត្រូវមានពលិកម្ម អត់ធ្មត់ ខិតខំ ការតស៊ូ និង ព្យាយាម។

- តំណាក់កាលទី៥៖ ការបែងចែកផលលាភដោយតម្លាភាព និង យុត្តិធម៌។